# ការសម្ភាសរបស់ ហង្ស ចាន់ធី

ក. អ្នកសម្ភាស ខ. ហង្ស ចាន់ធី

ក. តើបងឈ្មោះពេញរបស់បងឈ្មោះអីគេដែរ?

ខ. ហង្ស ចាន់ធី។

ក. ហង្ស ចាន់ធី! ហើយហ្នឹងឈ្មោះត្រូវនឹងអត្តសញ្ញាប័ណ្ណបងមែនទេ?

ខ. ចា៎!

ក. បងមានឈ្មោះហៅក្រៅទេ?

ខ. ហៅក្រៅដូចគ្នាហ្នឹងដែរ ចាន់ធី។

ក. អញ្ចឹងឈ្មោះពីកុមារភាពបងមានណាគេហៅឈ្មោះអីផ្សេងទៀតទេ?

ខ. ហៅចាក់ឆេន។

ក. ចាក់ចេនបាទ! តើបងធ្លាប់រៀនភាសាណាក្រៅពីភាសាខ្មែរទេ?

ខ. អត់។

ក. អត់ទេ។ បងចេះសរសេរភាសាខ្មែរច្បាស់លាស់មែនទេ ល្អ?

ខ. អាចហៅថាល្អដែរតែវាមិនច្បាស់មួយរយភាគរយទេ។

ក. បាទ! ហើយបងកើតនៅណាដែរបង?

ខ. ខ្ញុំកើតនៅភ្នំពេញ។

ក. ភ្នំពេញ ភូមិអីគេដែរ? ស្រុកអីដែរ?

ខ. ភូមិ២២ ផ្លូវរទេះភ្លើង ខណ្ឌទួលគោក។

ក. ខណ្ឌទួលគោក។ ហើយបងឥឡូវបងមានអាយុប៉ុន្មានហើយ?

ខ. ៣០ឆ្នាំ។

ក. ៣០ឆ្នាំ។ បងកើតនៅឆ្នាំណាដែរ?

ខ. នៅឆ្នាំ១៩៨៦

វ. ៨៦។ ហើយត្រូវជាឆ្នាំអីគេខាងសុរិយគតិ?

ខ. ឆ្នាំថោះ។

ក. ឆ្នាំថោះ។ ហើយបងអត់ទាន់រៀបអាពាហ៍ពិពាហ៍ទេ?

ខ. នៅ។

ក. បាទ។ ហើយ អញ្ចឹង សំណួរចង់សួរបងបន្តទៀតថា តើបងមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ. ប្រាំនាក់។

ក. ប្រាំនាក់។ ប្រុសម៉ានស្រីម៉ាន?

ខ. ស្រីពីរ ប្រុសបី។

ក. ស្រីពីរ ប្រុសបី។ ហើយឥឡូវក្រុមគ្រួសាររបស់បងយ៉ាងម៉េចដែរ?

ខ. ឥឡូវហ្នឹងហ្ន៎?

ក. មានការលំបាកឬក៏...

ខ. វាមានការលំបាក។

ក. បងគិតថាវាលំបាកយ៉ាងម៉េចដែរ?

ខ. លំបាកត្រង់ថាក្រុមគ្រួសាររស់នៅអត់ចុះសម្រុងគ្នា។ ហើយលំបាកត្រង់ការផ្គត់ផ្គង់ជីវភាពតែប៉ុណ្ណឹង។

ក. បាទ។ ហើយតើបងដឹងអ្វីខ្លះពីឪពុកម្តាយរបស់បង? តើពួកគាត់កើតនៅថ្ងៃណាឆ្នាំណាបងដឹងទេ?

ខ. តាមពិតខ្ញុំអត់បានចាប់អារម្មណ៍នៅថ្ងៃកំណើតរបស់ប៉ាម៉ាក់ផង។

ក. បាទ។ អញ្ចឹងពួកគាត់ឈ្មោះអីគេដែរបង?

ខ. ឪពុករបស់ខ្ញុំឈ្មោះហង្ស សុឃឿន។

ក. ហង្ស សុឃឿន។ ហើយម្តាយ?

ខ. ម្តាយឈ្មោះអម ច័ន្ទស្រីផល

ក. តើបងដឹងថាឥឡូវគាត់អាយុប៉ុន្មានហើយ ឪពុក?

ខ. ប៉ាខ្ញុំអាយុហាជាង។

ក. ហាជាង។ ហើយម៉ាក់?

ខ. ម៉ាក់អាយុសែជាង។

ក. បាទ។ គាត់ដូចជាកើតឆ្នាំអីគេ?

ខ. ខ្ញុំអត់ចាំ...អ៊ូ ឆ្នាំនេះហ្ន៎? ម៉ាក់ខ្ញុំឆ្នាំរក ឆ្នាំស្វា។

វ. ឆ្នាំស្វា។ ហើយប៉ា?

ខ. ប៉ាឆ្នាំឆ្លូវ គោ

វ. គោ។ ហើយតើបងចាំអ្វីខ្លះអំពីជីដូនជីតារបស់បងទេ? ប៉ាម៉ាក់បងធ្លាប់ប្រាប់និយាយអីខ្លះទេ?

ខ. ហ្នឹងហើយ ខ្ញុំចាំបាន។ ពីតារបស់ខ្ញុំខាងប៉ា ប៉ាបាននិយាយប្រាប់ថាគាត់ គឺជាពីឡុត (អ្នកបើកយន្តហោះ) ពីសម័យមុន។

គាត់គឺជាពីឡុតហើយគាត់គឺជាមនុស្សដែលអស្ចារ្យបំផុត។ នៅស្រុក
នៅស្រុកខេត្តកោះធំខេត្តកណ្ដាល កោះធំគាត់បានសាងស្នាដៃមួយ
គាត់បានធ្វើព្រែកមួយឲ្យប្រជាជននៅហ្នឹងរស់នៅ ដើម្បីងាយស្រួល។
គេហៅថាព្រែកតាហោះ។

ក. ព្រែកតាហោះ។

ខ. ចា៎! ព្រែកតាហោះហ្នឹងហើយគឺជាស្នាដៃរបស់តារបស់ខ្ញុំ។

ក. បាទ!

ខ. អ្វីដែលខ្ញុំដឹងពីប៉ារបស់ខ្ញុំពីតារបស់ខ្ញុំថាតារបស់ខ្ញុំជាមនុស្សល្អ។

ក. បាទ!

ខ. ហើយគាត់បានធ្វើការច្រើនដើម្បីជួយមនុស្សនៅសម័យគាត់ហ្នឹងឲ្យស្រួល។
ហើយខ្ញុំស្រឡាញ់តារបស់ខ្ញុំ។

ក. ហើយខាងយាយម្ដង?

ខ. ហ្នឹងហើយតាខាងយាយខ្ញុំដឹងថា ម៉ាក់ខ្ញុំក៏បាននិយាយប្រាប់ខ្ញុំថាកាលពីសម័យហ្នឹង
តារបស់ខ្ញុំគឺជាប៉េអិម (ប៉ូលីស)។

ក. ប៉េអិម។

ខ. ហ្នឹងហើយ ហើយគាត់មានស្នាដៃចាប់ជនល្មើសច្រើន។

ក. បាទ!

ខ. ហ្នឹងហើយ ហើយគាត់ជាមនុស្សដែលកាច់បំផុតម៉ឺងម៉ាត់បំផុត ប៉ុន្តែគាត់កាន់យុត្តិធម៌
ធ្វើការសុចរិតបំផុត អត់មានស៊ីសំណូកអីទាំងអស់។ ដូចពីសម័យតារបស់ខ្ញុំហ្នឹង
ហើយខ្ញុំនឹកចាំ
អំពីពាក្យសម្ដីម៉ាក់ខ្ញុំនិយាយពីតារបស់ខ្ញុំថាគាត់ជាមនុស្សម៉ឺងម៉ាត់ហើយគាត់ស្រឡាញ់ភាពយុត្តិធម៌បំផុត។ ជាចំណុចមួយហ្នឹងដែលខ្ញុំចងចាំពីតារបស់ខ្ញុំ
ហើយខ្ញុំសរសើរពីស្នាដៃរបស់គាត់ដែរ។

ក. បាទ! អញ្ចឹងហើយខាងយាយវិញបង?

ខ. យាយរបស់ខ្ញុំខាងតាគាត់ជាស្ត្រីម្នាក់ធម្មតាប៉ុន្តែកាលមុនគាត់ធ្វើការនៅវាំង។

ក. វាំង។

ខ. គាត់ជា គេហៅថាភីលៀង។

ក. បាទ ភីលៀង។

ខ. ហ្នឹងភីលៀងក្នុងវាំង។ គាត់រស់នៅមានរបៀបរៀបរយបំផុតនៅក្នុងផ្ទះ។
ខ្ញុំដឹងថាគាត់ជាមេផ្ទះល្អហើយគាត់បានមើលថែប៉ារបស់ខ្ញុំបានល្អដែរ។

ក. បាទ។

ខ. តែបើការនិយាយក៏អត់មានទេ គ្រាន់តែប៉ុណ្ណឹង។

ក. មានអីទៀតទេបង?

ខ. ហ្នឹងហើយរីឯយាយខាងម៉ាក់គាត់ជាមនុស្សក្រម្សត់។ ដោយសារតែតាខ្ញុំឆាប់ខូចពីជំនាន់ហ្នឹង។ ហើយពេលដែលតាខ្ញុំខូច យាយរបស់ខ្ញុំនៅកូនតូចៗដល់ទៅបីនាក់ ហើយគាត់ក្លាយជាស្រ្តី មេម៉ាយ ហើយគាត់អត់មានចេះអក្សរអីទេ។ អញ្ចឹងគាត់បានប្រើកម្លាំងរបស់គាត់ដើម្បីរកស៊ី ចិញ្ចឹមម៉ាក់របស់ខ្ញុំហើយនិងអ៊ុំៗរបស់ខ្ញុំ។ គាត់បានបាវស្ករ គាត់លើកស្ករទាំងធុងៗដាក់ក្នុង ឡានគេ។ គាត់បានប្រើកម្លាំង ហើយគាត់បានធ្វើកិច្ចការធ្ងន់ៗជាច្រើនដើម្បីចិញ្ចឹមម៉ាក់របស់ខ្ញុំហើយនិងអ៊ុំរបស់ខ្ញុំរហូតដល់គាត់ធំ។ អញ្ចឹងខ្ញុំចងចាំពីយាយរបស់ខ្ញុំថាប្រវត្តិនៃការតស៊ូរស់នៅដោយចិញ្ចឹមកូនបីនាក់ជាស្រ្តីមេម៉ាយ គាត់អត់យកប្តីទៀតទេដោយសារគាត់ខ្លាចគេ ធ្វើបាប ម៉ាក់ហើយនឹងអ៊ុំៗរបស់ខ្ញុំ។ ខ្ញុំសរសើរគាត់។ គាត់ជាស្រ្តីម្នាក់ដែលទន់ភ្លន់ប៉ុន្តែរឹងមាំ។

ក. បាទ! អរគុណច្រើនបង។ បងដឹងថាពួកគាត់កើតនៅណាដែរ?

ខ. យាយរបស់ខ្ញុំគាត់កើតនៅកំពង់ស្ពឺ។

ក. កំពង់ស្ពឺ ខាងម្តាយទេ?

ខ. ខាងម្តាយ។

វ. បាទ! ហើយតា?

ខ. តាខ្ញុំចាំអត់ច្បាស់។

ក. បាទ! ហើយខាងឪពុកវិញ?

ខ. ខាងឪពុកគាត់នៅកោះធំ...

ក. គាត់នៅ...

ខ. ខេត្តកណ្តាល។

ក. បាទ ទាំងយាយទាំងតាមែនទេបង?

ខ. ហ្នឹងហើយ!

ក. បាទ បងដឹងថាពួកគាត់កើតនៅថ្ងៃណាឆ្នាំណា?

ខ. ខ្ញុំអត់ចាំ។

ក. អាយុម៉ានអី?

ខ. ខ្ញុំដឹងថាយាយខាងម៉ាក់របស់ខ្ញុំគាត់ខូចនៅអាយុហុកប្រាំបី។

ក. ខូចនៅអាយុហុកប្រាំបីម៉ានឆ្នាំហើយបង ខូចម៉ានឆ្នាំហើយ?

ខ. ចាំអត់បាន។

ក. ចាំអត់បានទេ។ ហើយអញ្ចឹង តើពួកគាត់ស្លាប់អស់ហើយមែនទេបង?
នៅតែប៉ាម៉ាក់សព្វថ្ងៃទេ។

ខ. ចាំ នៅតែប៉ាម៉ាក់ទេ។

ក. ហើយបង ទាក់ទងនឹងប៉ាម៉ាក់បងគិត បងពួកគាត់កើតនៅណាដែរ? ទាំងពីរនាក់។

ខ. ម៉ាក់របស់ខ្ញុំ ខ្ញុំអត់ដឹងថាគាត់កើតនៅកន្លែងណា ប៉ុន្តែធ្លាប់ដឹងថាពីតូចគាត់
នៅផ្សារដើមស្កូវ។

ក. ផ្សារដើមស្កូវបាទ ហើយប៉ា?

ខ. ប៉ានៅ...ដូចជានៅកំពង់ឆ្នាំង។

ក. គាត់កើតនៅកំពង់ឆ្នាំង។

ខ. គាត់...ខ្ញុំអត់ដឹងថាគាត់កើតនៅកំពង់ឆ្នាំងអត់ប៉ុន្តែគាត់ធ្លាប់...អ៎ូហ្នឹងហើយ ស្រុកកំណើត
គាត់កំពង់ឆ្នាំង។ គាត់និយាយប្រាប់ខ្ញុំ។

ក. បាទ! ភូមិបងភូមិអីគេដែរ?

ខ. អត់ដឹង!

ក. អត់ដឹងទេ។ បាទ អញ្ចឹងពួកគាត់កើតនៅស្រុកខ្មែរទាំងអស់គ្នា ហើយពួកគាត់ធ្លាប់ទៅ នៅ
ប្រទេសក្រៅទេបង? ទៅលេងទៅអីអញ្ចឹង?

ខ. អត់។

ក. អត់ទេ។ អញ្ចឹងឥឡូវទាក់ទងនឹងជីវិតរបស់បងវិញ។ អញ្ចឹងបងអាចប្រាប់ខ្ញុំបានអំពីទាក់ទង
នឹងជីវិតរបស់បងពេលធំឡើង តើវាយ៉ាងម៉េចដែរ?

ខ. ពេលធំឡើងហ្ន៎?

ក. បាទ! ដូចជា...ឥឡូវបងនិយាយសិនមកចាំមានសំណួរក្រោយផ្សេងទៀត។

ខ. អត់ដឹងឆ្លើយយ៉ាងម៉េច។

ក. បង ជាពេលបងធំឡើងបងយ៉ាងម៉េចដែរជីវិតរបស់បង?

ខ. សម្រាប់ជិវិតខ្ញុំពេលខ្ញុំធំដឹងក្តីឡើងខ្ញុំមានទំនួលខុសត្រូវច្រើន។ តាមពិតខ្ញុំអត់ចង់និយាយ
ពីពេលធំឡើងប៉ុន្តែខ្ញុំនិយាយពីកាលខ្ញុំនៅក្មេង។

ក. បាទ!

ខ. ហ្នឹងហើយ កាលពីខ្ញុំនៅក្មេងខ្ញុំបានប្តេជ្ញានៅក្នុងចិត្តថាធំឡើងខ្ញុំនឹងតបស្នងសង់គុណ
ឪពុកម្តាយរបស់ខ្ញុំ
ហើយខ្ញុំនឹងព្យាយាមធ្វើកិច្ចការជាច្រើនដើម្បីជួយឲ្យពួកគាត់បានធូរស្រាល។
ដោយសារកាលពីនៅក្មេង ឪពុករបស់ខ្ញុំគាត់ធាក់ស៊ីក្លូ។
អញ្ចឹងនៅពេលដែលខ្ញុំបានឃើញឪពុករបស់ខ្ញុំនៅផ្សារអូរឫស្សី
គាត់បានធាក់ស៊ីក្លូហើយប៉ាខ្ញុំគាត់បានអត់មើល ឃើញខ្ញុំទេប៉ុន្តែខ្ញុំបាន មើលឃើញគាត់។
អញ្ចឹងបានសម្លឹងនូវភាពនឿយហត់របស់ឪពុករបស់ខ្ញុំ។ គាត់បានធាក់ស៊ីក្លូ

នៅកណ្តាលថ្ងៃហើយ គាត់បានលើកឥវ៉ាន់ធ្ងន់ៗ។ ខ្ញុំខ្លោចផ្សាចិត្តបំផុតហើយខ្ញុំបានប្តេជ្ញានៅក្នុងចិត្តខ្ញុំថាធំឡើងខ្ញុំធ្វើអ្វីក៏បានដែរឲ្យតែខ្ញុំអាចជួយឪពុករបស់ខ្ញុំឲ្យគាត់បានធូរស្បើយនឹងកម្លាំង។ ប៉ុន្តែនៅពេលដែលខ្ញុំធំចំណេះវិជ្ជារបស់ខ្ញុំវាតិច ខ្ញុំមិនអាចរកប្រាក់ចំណូលជួយដើម្បីឲ្យ គាត់មានភាពស្រណុកសុខស្រួលដូចគេទេ។

ក. បាទ!

ខ. ប៉ុន្តែខ្ញុំព្យាយាមប្រើកម្លាំងរបស់ខ្ញុំ ប្រើកម្លាំងរបស់ខ្ញុំទាំងមូលនេះប្រកបកិច្ចការងាររកស៊ីដើម្បីជួយពួកគាត់។ ទោះបីជាវានឿយហត់ប៉ុន្តែខ្ញុំសប្បាយចិត្តនឹងញើសឈាមរបស់ខ្ញុំដែលខ្ញុំអាចជួយម៉ាក់ប៉ារបស់ខ្ញុំបាន។

ក. បាទ អរគុណច្រើនបង។ បងមានអីបន្ថែមទៀតទេ?

ខ. អត់ទេ!

ក. អញ្ចឹងចង់សួរបងកាលដែលតើបងរៀននៅ កាលពេលដែលបងរៀននៅសាលាតើបងរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ខ. ខ្ញុំរៀនបានថ្នាក់ទីប្រាំពីរ។

ក. នៅសាលាឈ្មោះអីគេដែរបង?

ខ. មុនដំបូងខ្ញុំរៀននៅសាលានាគវន្ត បឋមសិក្សានាគវន្ត។ នៅពេលដែលខ្ញុំឡើងវិទ្យាល័យថ្នាក់ទីប្រាំពីរវិទ្យាល័យ នៅឥន្ទ្រទេវី។ ខ្ញុំចូលរៀនបានបីខែវិទ្យាល័យទីប្រាំពីហ្នឹង។ ហើយដោយសារ តែជីវភាពក្រុមគ្រួសាររបស់ខ្ញុំអត់ ខ្ញុំបានឈប់រៀន។

ក. បាទ! តើកាលហ្នឹងបងមានលុយប៉ុន្មានដើម្បីទៅរៀនដែរបង?

ខ. ថ្ងៃខ្លះខ្ញុំមាន...ម៉ាក់ខ្ញុំគាត់តែងតែឲ្យខ្ញុំប្រាំរយទៅរៀន។ ហើយពេលខ្លះអត់មានទេ។ ពេលខ្លះអត់មានទេ។

ក. បាទ អញ្ចឹងបងធ្លាប់ ដោយសារនៅភ្នំពេញទេអត់មានចម្ការទេ។ ហើយក្រុមគ្រួសាររបស់បងពេលដែលបងកាលហ្នឹងក្រុមគ្រួសាររបស់បងជាអ្នករកស៊ីមែនទេ? ឬក៏អ្នកធ្វើការមែនទេ?

ខ. សួរម្តងទៀតស្តាប់អត់បាន?

ក. ចង់និយាយថាពេលដែលបងនៅពីតូចហ្នឹងពេលដែលបងទៅរៀនហ្នឹង គ្រួសាររបស់បងជាអ្នកធ្វើការទាំងអស់គ្នាឬក៏ពួកគាត់ធ្វើអីគេដែរ? ទាំងអស់គ្នា។

ច. តាមពិតកាលពីខ្ញុំនៅរៀនអ្នករកមានតែមួយទេ។ គឺប៉ារបស់ខ្ញុំគាត់ធាក់ស៊ីក្លូ។ ហើយម៉ាក់ខ្ញុំគាត់ជាមេផ្ទះ។

ក. បាទ! តើជីវិតរបស់បង តើជីវិតសព្វថ្ងៃតើវាខុសគ្នាយ៉ាងម៉េចដែរពីមុនហ្នំ? ពេលដែលបងនៅក្មេង សព្វថ្ងៃវាខុសគ្នាយ៉ាងម៉េចដែរ?

ខ. ខុសគ្នាម៉េចមិញ?

ក. ចង់និយាយថា ជីវិតរបស់បងសព្វថ្ងៃហ្នឹងហើយពេលដែលជីវិតរបស់បងនៅក្មេងហ្នឹង តើវាខុសគ្នារបៀបម៉េចដែរ?

ខ. ខុសគ្នាត្រង់ថាកាលពីខ្ញុំនៅក្មេងខ្ញុំអត់សូវគិតច្រើនបញ្ហាក្រុមគ្រួសារទេ។

ក. បាទ!

ខ. ប៉ុន្តែនៅពេលដែលខ្ញុំដឹងក្តី ខ្ញុំបានមានគំនិតគិតច្រើនពីក្រុមគ្រួសាររបស់ខ្ញុំ។ ដូចខ្ញុំនិយាយខាងលើមិញថាខ្ញុំមានទំនួលខុសត្រូវដើម្បីរកស៊ីចិញ្ចឹមក្រុមគ្រួសាររបស់ខ្ញុំរបស់ប៉ាម៉ាក់ខ្ញុំហ្នឹង។

ក. បាទ!

ខ. អញ្ចឹងដូចជាខ្ញុំបាននិយាយខាងលើម៉េចថាបងប្អូនរបស់ខ្ញុំមានប្រាំនាក់។ ប៉ុន្តែបងប្រុសរបស់ខ្ញុំគាត់មានក្រុមគ្រួសារហើយមានកូនប្រាំមួយនាក់។

ក. បាទ!

ខ. អញ្ចឹង
ប៉ុន្តែបងប្រុសរបស់ខ្ញុំអត់មានសមត្ថភាពដើម្បីរកស៊ីចិញ្ចឹមកូនៗដល់ប្រាំមួយហ្នឹងទេ។ អញ្ចឹងបន្ទុកកូនដល់ប្រាំមួយគឺត្រូវធ្លាក់មកលើខ្ញុំប៉ាម៉ាក់ទៀត។

ក. បាទ!

ខ. ហើយប្អូនប្រុសរបស់ខ្ញុំពីរនាក់ហើយនិងស្រីម្នាក់ទៀត សម័យនេះដូចដឹងហើយថាជាសម័យ មួយដែលជ្រុលច្របល់បំផុត។ ប្រទេសខ្មែរមានគ្រឿងញៀនច្រើនអញ្ចឹងប្អូនរបស់ខ្ញុំបានធ្លាក់ នៅក្នុងរឿងអស់ទាំងហ្នឹង។ ប្អូនប្រុសមួយគាត់ឆ្កួតនឹងគ្រឿងញៀន។ គាត់ធ្លាក់ខ្លួនសរសៃ ប្រសាទដោយសារតែគ្រឿងញៀន។ ប្អូនស្រីខ្ញុំមួយទៀតក៏គាត់ធ្លាក់ខ្លួនដោយសារតែគ្រឿង ញៀន។ ប្អូនប្រុសខ្ញុំមួយទៀតដោយសារអាយុក្មេងទំនើងគាត់បានប្រព្រឹត្តរឿងដ៏ខុសឆ្គងរហូត ដល់រត់ចោលស្រុក។
អញ្ចឹងខ្ញុំមានអារម្មណ៍ថាក្រុមគ្រួសាររបស់ខ្ញុំបែកខ្ញែកគ្នាអស់។ ទោះបីជាខ្ញុំមានបងប្អូនប្រាំនាក់ប៉ុន្តែខ្ញុំមានអារម្មណ៍ថានៅក្នុងផ្ទះមានតែខ្ញុំម្នាក់។ ខ្ញុំត្រូវគិតច្រើនពីគាត់ ណាគិតពីឪពុកម្តាយ ណាគិតពីបងផង។ ខ្ញុំអត់ចង់និយាយទៀតទេ។

ក. បាទ អរគុណបង។ អញ្ចឹងតើពីក្មេងបងចូលចិត្តម្ហូបអីគេដែរ?

ខ. ខ្ញុំចូលចិត្តចៀនចូន។

ក. ចៀនចូន បាទ។ ហើយមានហ្គេមល្បែងណាដែលបងចូលចិត្តអីទេពីក្មេង?

ខ. ខ្ញុំអត់ចូលចិត្ត។

ក. អត់មានសោះហ្មង?

ខ. អត់មានសោះហ្មង។

ក. អត់មានល្បែងប្រជាប្រិយអីណា?

ខ. អត់!

ក. អត់ទេ។ តើពីក្មេងបងបានរៀនរបៀបដើម្បីធ្វើចម្អិនម្ហូបអីទាក់ទងម្ហូប?

ខ. ខ្ញុំរៀន។ ខ្ញុំរៀនច្រើនពីម៉ាក់។ គាត់បង្រៀនខ្ញុំ។

ក. បងដូចចាំពីមួប។ អញ្ចឹងបងសម្រាប់បទចម្រៀងវិញ តើបងមានបទចម្រៀងណាដែលបងចូលចិត្តទេ? រៀនច្រៀងពីក្មេង។

ខ. កាលពីក្មេងហ្ន៎? ខ្ញុំចូលចិត្តជាងគេគឺ បទអ...ខ្ញុំអត់ដឹងថាចំណងជើងអីតែវាពាក់ព័ន្ធនឹងអ្នកម្ដាយ។

ក. គុណម៉ែទេ?

ខ. ហ្នឹងហើយ!

ក. គុណម្ដាយហ្នឹងហើយ។ ខ្ញុំចូលចិត្តបទហ្នឹងដែរ។

ខ. ខ្ញុំចូលចិត្តវាជាងគេពីនៅក្មេង។

ក. តើក្រុមគ្រួសាររបស់បងមាននរណាមួយដែលគាត់ចេះផលិតឧបករណ៍ភ្លេងទេ?

ខ. អត់មាន!

ក. អត់មានទេ។ តើផ្ទះរបស់បងយ៉ាងម៉េចដែរ? ធ្វើពី...

ខ. ពីឈើ

ក. ធ្វើពីឈើ។ ហើយបងជាអ្នកកសាងវាសាងសងវាឬក៏...

ច. តាមពិតបើសិនជាផ្ទះហ្នឹងខ្ញុំមិនមែនជាអ្នកកសាងទេ ប៉ុន្តែវាជាកម្លាំងពីការរករបស់ខ្ញុំ។

ក. បាទ! អញ្ចឹងកម្លាំងរបស់បងរកតែពេលដែលសាងសងផ្ទះហ្នឹង បងមានបានជួយពួកគេធ្វើទេ? ធ្វើផ្ទះរបស់បងទេ?

ខ. ខ្ញុំអត់ជួយធ្វើប៉ុន្តែខ្ញុំជួយលើកឈើ។

ក. ជួយលើកឈើ អញ្ចឹងខ្ញុំគិតថាជួយដែរ។ អាចមានន័យថាបងអាចបានជួយធ្វើផ្ទះដែរ។ តើផ្ទះឥឡូវរបស់បងម៉េចដែរ រឹងមាំដែល?

ខ. រឹងមាំ។

ក. បាទ!

ខ. ថ្វីត្បិតថាវាចង្អៀតតែវាមាំ។

ក. អញ្ចឹងផ្ទះហ្នឹងមិនមែនប៉ាបងអ្នកសាងសងមែនទេ? ឬក៏...

ខ. ម៉េច? ជា...មិនមែនជាប៉ាដោយសារតែគាត់គ្មានកម្លាំងដើម្បីធ្វើម្នាក់ឯងទេ។ គាត់បានជួលជាងមកធ្វើ។

ក. តើផ្ទះក្រុមគ្រួសាររបស់បងតើមានណាគេមានជំនាញអីមួយ ធ្វើអីមួយទេ?

ខ. មាន បងប្រុសរបស់ខ្ញុំគាត់ជំនាញជាងឈើ។

ក. ជាងឈើ។ មានណាគេជំនាញត្បាញឬក៏ធ្វើស្ករត្នោតឬក៏អីផ្សេងទៀតទេ?

ខ. អត់មានទេប៉ុន្តែម៉ាក់ខ្ញុំគាត់ជំនាញខាងឌិន។

ក. ខាងឱន។

ខ. ផ្នែកដេរប៉ាក់ឱនអីហ្នឹងហ្ន៎

ក. បាទ!

ខ. គាត់ជំនាញ។

ក. វាខុសពីត្បាញមែនទេ?

ខ. ខុសគ្នា។

ក. អញ្ចឹងឥឡូវចូលសំណួរមួយទៀត បញ្ហាទាក់ទងនឹងបញ្ហាប្រឈមមុខ។ បងអាចប្រាប់ខ្ញុំបាន អំពីពេលវេលាមួយដ៏លំបាកបំផុតនៅក្នុងជីវិតរបស់បងទេ?

ខ. ពេលវេលាមួយដែលលំបាកបំផុតនៅក្នុងជីវិតរបស់ខ្ញុំ?

ក. បាទ។ ហើយប្រាប់ថាតើបងឆ្លងកាត់វាដោយរបៀបណា?

ខ. តាមពិតខ្ញុំមានភាពលំបាកច្រើនប៉ុន្តែពេលវេលាដ៏លំបាកខ្ញុំចាំបានថា ពេលវេលាដែលខ្ញុំលំបាក ខ្លាំង បំផុតនៅពេលដែលខ្ញុំបានឃើញប្អូនរបស់ខ្ញុំត្រូវប៉ូលីសចាប់។ អាចរាប់ជាការលំបាកមែនអត់?

ក. អាចបានបើសិនបងគិតថាវាលំបាកបំផុតសម្រាប់បងអារម្មណ៍ឬក៏ស្ថានភាព។

ខ. ហ្នឹងហើយ!

ក. បាទ!

ខ. វាជាពេលមួយដែលមិនមែនត្រឹមតែខ្ញុំទេប៉ុន្តែប៉ាម៉ាក់ខ្ញុំក៏លំបាកខ្លាំងណាស់។ នៅពេលហ្នឹង ជាពេលពាក់កណ្តាលអាធ្រាត្រ ខ្ញុំបានអ...ដាស់ប្អូនខ្ញុំដោយសារខ្ញុំប្រកបជីវភាពនៅពេលយប់ ខ្ញុំ ដើបធ្វើពេលយប់។ ខ្ញុំបានដាស់ប្អូនខ្ញុំប្រុសទីបីបន្ទាប់ពីខ្ញុំហ្នឹង ឲ្យគាត់ងើបដាំទឹកយកទៅឲ្យខ្ញុំហ្នឹងលាងស្បៀសនៅខាងលើ។ ហើយខ្ញុំអត់ដឹងថានៅពេលហ្នឹងក្រុមប៉ូលីសហ្នឹង គេចុះមកបង្ក្រាប ជនគ្រឿងញៀនទេ។

ក. បាទ!

ខ. នៅពេលហ្នឹងប្អូនខ្ញុំគាត់អត់ទាន់ចេះលេងគ្រឿងញៀនទេ។ អញ្ចឹងប្អូនខ្ញុំបានឃើញគេរត់ហើយប្អូនខ្ញុំភ័យគាត់បានរត់ដែរ។ គាត់បានចុះមកក្រោមដល់កាំជណ្តើរផ្ទះហើយ ហើយគាត់គិត ថាលែងអីទេ។ អញ្ចឹងនៅពេលហ្នឹងខ្ញុំបានមកចុះមកដោយសារឮសំឡេងឈ្លោះ។ នៅពេលចុះមក ខ្ញុំឃើញប៉ូលីសពាក់សុទ្ធតែកាំភ្លើង បានក្រៀកប្អូនខ្ញុំដាក់ខ្នោះដៃប្អូនខ្ញុំចាប់យកទៅ។ ខ្ញុំចាំបានថាអារម្មណ៍ខ្ញុំមួយហ្នឹង វាពិបាកខ្លាំងបំផុតដោយសារខ្ញុំអត់ដឹងថាប្អូនខ្ញុំខុសអីទេ។ អញ្ចឹងគេបង្ខិនចាប់ប្អូនខ្ញុំយកទៅ ប្អូនខ្ញុំបានស្រែកឲ្យខ្ញុំហើយនឹងប៉ាម៉ាក់ជួយផង ប៉ុន្តែខ្ញុំអត់មានសមត្ថភាពដើម្បីជួយគាត់។ ខ្ញុំចាំបានថាពេលឡានប៉ូលីសចេញ គេចាប់ប្អូនខ្ញុំបណ្តើរទៅចូលឡើងឡានប៉ូលីសហ៎?

ក. បាទ!

ខ. ខ្ញុំបានរត់តាមឡានប៉ូលីសហ្នឹង។ ខ្ញុំបានរត់ខ្លាំងមែនទែន ខ្ញុំបានទៅទ្រហ៊ុយំ ខ្ញុំហៅឲ្យដោះលែងប្អូនខ្ញុំ ប៉ុន្តែប៉ូលីសហ្នឹងអត់បានដោះលែងប្អូនខ្ញុំទេ។ ពេញមួយយប់ហ្នឹងខ្ញុំអត់បានដេក ហើយខ្ញុំបានសំដៅទៅកន្លែងដែលគេចាប់ឃុំប្អូនខ្ញុំហ្នឹង។ ខ្ញុំបានលុតជង្គង់អង្វរដល់ប៉ូលីសហ្នឹង ឲ្យដោះលែងប្អូនរបស់ខ្ញុំ។
ខ្ញុំចាំបានថាអារម្មណ៍មួយនេះជាពេលលំបាកខ្លាំងបំផុត។ ខ្ញុំភ័យខ្លាច ប្អូន ខ្ញុំជាប់គុក។ និយាយរួមទៅបើសិនជាគេផ្សេងប្រហែលវាគ្រាន់តែជារឿងធម្មតា។ ប៉ុន្តែដឹង ទេ? ខ្ញុំអត់ដឹងថាថីបានជីវិតរបស់ខ្ញុំកើតមកខ្ញុំ ស្រឡាញ់បងប្អូន របស់ខ្ញុំដល់ថ្នាក់ ហ្នឹងទេ។ ខ្ញុំស្រឡាញ់ពួកគាត់ខ្លាំង។
ពេលខ្លះខ្ញុំសុខចិត្តឲ្យភាពលំបាកអស់ទាំងហ្នឹងធ្លាក់មកលើខ្ញុំល្អជាជាងឲ្យខ្ញុំបើកភ្នែកឃើញពួកគាត់លំបាក។ ហើយមានរឿងជាច្រើនទៀតប៉ុន្តែខ្ញុំយកតែមួយហ្នឹងបានហើយ។

ក. បាទ អរគុណបង។ តើបងឆ្លងកាត់ពេលវេលាទាំងអស់ហ្នឹងដោយរបៀបម៉េចទៅ?

ខ. បើសម្រាប់ខ្ញុំនៅពេលហ្នឹងអ្វីដែលខ្ញុំគិតដល់
យើងគ្មានខ្នល់ប់ផ្អែកជាអ្នកដែលមានអំណាចដើម្បីជួយខ្ញុំបានទេ។
ប៉ុន្តែនិយាយទៅហាក់បីដូចជាមិនជឿ។
នៅពេលហ្នឹងអ្វីដែលខ្ញុំនឹកឃើញហ្នឹងគឺព្រះតែប៉ុណ្ណឹង។
ខ្ញុំបានពឹងផ្អែករឿងទាំងអស់ហ្នឹងទៅលើព្រះទាំងអស់។
ហើយខ្ញុំសង្ឃឹមថានៅពេលដែលយើងធ្វើសេចក្តីសុចរិត
រឿងអាក្រក់ៗហ្នឹងមិនកើតមានយូរសម្រាប់យើងទេ។
ហើយខ្ញុំសង្ឃឹមថាព្រះទ្រង់នឹងអាចជួយខ្ញុំបាន។
ការពិតនៅគ្រាហ្នឹងបើសិនជាខ្ញុំអត់ដឹងថាមានព្រះ ម្ល៉េះខ្ញុំមិនដឹងរស់នៅយ៉ាងណា?
ចុះពេញមួយយប់ហ្នឹងខ្ញុំបាន ខ្ញុំបានគិតដល់ពីព្រះជានិច្ច។

ក. បាទ អញ្ចឹងនេះជារបៀបដែលបងឆ្លងកាត់វា។ អញ្ចឹងទាក់ទងនឹងបទពិសោធមួយល្អវិញ។ តើបងគិតថាមានអ្វីដែលជាបទពិសោធល្អ អ្វីដែលល្អបំផុតដែលបងមានក្នុងជីវិតទេ?

ខ. បទពិសោធល្អ?

ក. អ្វីដែលបងចូលចិត្តនៅក្នុងជីវិតរបស់បងដែលល្អបំផុត ដែលធ្វើឲ្យបងសប្បាយចិត្ត។ ចងចាំមិនអាចបំភ្លេចបានអញ្ចឹងហ្ន៎។

ខ. ស្ទើរតែគ្មាន ខ្ញុំគិតសិន។

ក. ដូចជារំភើបខ្លាំង ដូចជាឧទាហរណ៍ថាឥឡូវក្មួយប្រុសយើងកើតមកអញ្ចឹងឬក៏...

ខ. អ៎! ហ្នឹងហើយ។ តាមពិតអ្វីដែលខ្ញុំរំភើបខ្លាំង ខ្ញុំជាមនុស្សម្នាក់ដែលស្រឡាញ់ក្មេង។ អញ្ចឹងដោយសារតែបងប្រុសរបស់ខ្ញុំហ្នឹងគាត់អត់មានកូនប្រុសទេអញ្ចឹងហ្ន៎។

ក. បាទ។

ខ. គាត់អត់មានកូនប្រុសទេ។ អញ្ចឹងបំណងប្រាថ្នារបស់គាត់គឺចង់បានកូនប្រុស។
ហើយខ្ញុំក៏ចង់បានក្មួយប្រុសដែរ។ អញ្ចឹងនៅពេលដែលកើតមកក្មួយ
ខ្ញុំប្រុសដែរហើយមានដល់ទៅពីរ! អញ្ចឹងជារឿងមួយដែលខ្ញុំរំភើបខ្លាំងបំផុត។

ក. បាទ! ល្អមែនទែនបង! អញ្ចឹងសម្រាប់បង បងអត់ទាន់បានរៀបអាពាហ៍ពិពាហ៍ទេ
ហើយចង់សួរសំណួរមួយទៀតសួរថា តើអ្វីដែលបងសង្ឃឹមចង់ធ្វើវានៅពេលដែលបងធំឡើង?

ខ. អ្វីដែលខ្ញុំសង្ឃឹមចង់ធ្វើវានៅពេលដែលខ្ញុំធំឡើងហ្ន៎?

ក. បាទ! អ្វីដែលបងចង់ធ្វើនៅពេលធំឡើងពីក្មេង។

ខ. និយាយរួមទៅបំណងខ្ញុំតាំងពីក្មេងគឺខ្ញុំគ្រាន់តែចង់ធ្វើជាអ្នកលក់ដូរម្នាក់។
អញ្ចឹងបំណងខ្ញុំវាតូចបំផុតជាអ្នកពូកែខាងការងាររកស៊ី។

ក. បាទ!

ខ.ហើយខ្ញុំចង់ធ្វើការងាររកស៊ីដោយបើកចាប់ហួយមួយខ្នាតធំនេះជាបំណងប្រាថ្នារបស់ខ្ញុំតាំងពីក្មេង។

ក. បាទ មានអីផ្សេងទៀតទេបង?

ខ. មានមួយទៀតដែរប៉ុន្តែនិយាយដូចវាអៀន ខ្ញុំចង់ធ្វើអ្នកចំរៀង។ នេះជាបំណងតាំងពីក្មេង។

ក. បាទ ខ្ញុំគិតថាសម្លេងបងពិរោះ។

ខ. ហ៎ហ៎! ប៉ុន្តែរូបរាងអត់បាន ហ៉ាហ៉ាហ៉ា។

ក. អាចថតតែសម្លេងបាន។ អញ្ចឹងអ្វីទាំងអស់ហ្នឹងវាអ្វីសំណួរដែលយើងមានថ្ងៃហ្នឹង
មានតែប៉ុណ្ណឹងទាក់ទងជីវិតរបស់បង។
ប៉ុន្តែអ្វីដែលចុងក្រោយដែលខ្ញុំចង់និយាយទៅកាន់បងគឺចង់សូមអរគុណបងសម្រាប់ការនិយាយមកកាន់ខ្ញុំដែលថតជាសម្លេង....សម្លេងហ្នឹង។ ហើយអញ្ចឹងតើបងគិតយ៉ាងម៉េចដែរ បើសិនជាពួកយើងមានការផុសសម្លេងហ្នឹងនៅក្នុងវែបសាយមួយដែលផ្ទុកដោយការថតសម្លេងប្រជាជនខ្មែរនៅស្រុកខ្មែរយើងដែលទាក់ទងនឹងជីវិតរបស់ពួកគាត់ផ្ទាល់ខ្លួនបើបងយល់ព្រមដែរឬទេ? អនុញ្ញាតឲ្យផុស?

ខ. ខ្ញុំអនុញ្ញាតតើ។

ក. បាទ អនុញ្ញាត។ អញ្ចឹងអ្វីដែលផុសហ្នឹងគឺនៅក្នុងគេហទំព័ររបស់សាកលវិទ្យាល័យព្រិហ្គាំយ៉ុង ដែរ។ បងធ្លាប់ពួជាព្យាការីរបស់យើង ព្យាការីទីពីរហ្នឹង។
អញ្ចឹងសាកលវិទ្យាល័យហ្នឹងគេនឹង
បង្កើតគម្រោងណាហើយគេនឹងថតយកសម្លេងហ្នឹងដើម្បីផុសចូលក្នុងហ្នឹង។ ហើយសាកលវិទ្យាល័យហ្នឹងនឹងផ្តល់ឲ្យបងនូវច្បាប់ចម្លងការសម្ភាសហ្នឹងបើសិនជាចង់បានហើយមានន័យថាបងអាចស្តាប់វាពេលណាក៏បានដែរតាមវែបសាយហ្នឹង។ ហើយឬក៏យើងអាចពេលណាបើយើង ទំនេរអ៊ីយើងអាចឆែកចូលកន្លែងហ្នឹងស្រួលហ្មង។ អញ្ចឹងការសម្ភាស របស់ខ្ញុំមានតែប៉ុណ្ណឹង ថ្ងៃនេះ ហើយជាចុងក្រោយម្តងទៀតចង់និយាយថាពួកយើង សូមអរគុណបងសម្រាប់ការ ចំណាយពេលវេលារបស់បងដែលបានសម្ភាសថ្ងៃហ្នឹង។
ហើយអញ្ចឹងសូមអរគុណបង សូមជម្រាបលា!